# ៦_ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## ប្រកាស

### ប្រកាសលេខ ២០៧ ប្រក.សកប
### ស្តីពីការបង្កើតការិយាល័យអាស៊ាន ចំណុះអគ្គនាយកដ្ឋាន
### ទីស្តីការក្រសួងសាធារណការ និងដឹកជញ្ជូន

* * *

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណៈការ និង ដឹកជញ្ជូន

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១.១១.១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១.១០.១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹតលេខ ៣២.អនក្រ.បក ចុះថ្ងៃទី ២៥.០៦.១៩៩៦ ស្តីពីការចាត់តាំង និងការប្រព្រឹត្តទៅនៃប្រព័ន្ធសំរបសំរួលផ្ទៃក្នុង

### សំរេច

**ប្រការ១** : ត្រូវបានបង្កើតការិយាល័យកិច្ចការអាស៊ាន (ASEAN Urlit) ចំណុះអគ្គនាយកដ្ឋានទីស្តីការក្រសួងសាធារណការ និង ដឹកជញ្ជូន ។

**ប្រការ២** : ការិយាល័យកិច្ចការអាស៊ាន មានភារកិច្ចដូចតទៅ ÷

-វិភាគ និង គ្រប់គ្រងការងារអាស៊ាន ដែលទាក់ទិនផ្ទាល់ទៅនឹងសមត្ថកិច្ចរបស់ក្រសួង ។

-ធ្វើការសំរបសំរួល និង ទំនាក់ទំនងជាមួយស្ថាប័ននានា ព្រមទាំងជាមួយលេខាធិការដ្ឋាន ជាតិអាស៊ាន ដែលស្ថិតនៅក្នុងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

Downloaded from http://www.khmerlaws.com

**ប្រការ ៣** : ការិយាល័យកិច្ចការ អាស៊ាន ដឹកនាំដោយប្រធានការិយាល័យមួយនាក់ និង មានមន្ត្រី រាជការតាមតំរូវការចាំបាច់ ។

**ប្រការ ៤** : ឯកឧត្តម អគ្គនាយក លោកនាយកខុទ្ទកាល័យ ក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវ ទទួលបន្ទុកអនុវត្តន៍រៀងខ្លួន តាមខ្លឹមសារនៃប្រកាសនេះ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន
ហត្ថលេខា និង ត្រា
**អ៊ុង គៀត**

* * *

Downloaded from http://www.khmerlaws.com